# សន្និសីទចក្ខុវិស័យកម្ពុជាប្រចាំឆ្នាំ ២០០៨ :

# " ការកេណ្ឌប្រមូលធនធាននៅកម្ពុជា_ធនធានធម្មជាតិ

# ធនធានមនុស្ស ធនធានហិរញ្ញវត្ថុ

# សម្រាប់ការអភិវឌ្ឍន៍ប្រកបដោយគុណភាព

# ការរីកលូតលាស់ និងវិបុលភាព "

ថ្ងៃទី ២៨ ខែកុម្ភៈ ឆ្នាំ ២០០៨

សណ្ឋាគារភ្នំពេញ

# បទបង្ហាញ ស្តីពី

# " ការទាញផលប្រយោជន៍អោយបានប្រសើរបំផុត ពីធនធានធម្មជាតិនៅកម្ពុជា : ព្រៃឈើ និង ជលផល "


រៀបចំដោយ

ឯកឧត្តម ច័ន្ទ តុងអ៊ីវ

រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# ខ្លឹមសារបទបង្ហាញ

១. ក្របខ័ណ្ឌយុទ្ធសាស្ត្រ ិងកម្មវិធីនយោបាយ

២. សមិទ្ធិផល និងការអនុវត្តន៍ច្បាប់

៣. បញ្ហាប្រឈម

៤. វិធានការដោះស្រាយបន្ត

# ១. ក្របខ័ណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីនយោបាយ

- យុទ្ធសាស្ត្រចតុកោណរបស់រាជរាដ្ឋាភិបាល :
  - កំណែទម្រង់ព្រៃឈើ និងកំណែទម្រង់វិស័យនេសាទជាជ្រុងមួយនៃមុំទី១ របស់យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលអាណត្តិទី៣នរដ្ឋសភាដែលដឹកនាំដោយសម្តេចអគ្គមហាសេនាធិបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជានីតិកាលទី៣នៃរដ្ឋសភាបានកំណត់ដូចតទៅ :

# ១. វិស័យព្រៃឈើ :

- គ្រប់គ្រងព្រៃឈើប្រកបដោយចីរភាព ដោយមានការត្រួតពិនិត្យយ៉ាងម៉ឹងម៉ាត់ នូវការធ្វើអាជីវកម្មព្រៃឈើអោយបានសមស្របតាមនិយាមនៃការគ្រប់គ្រងព្រៃឈើអន្តរជាតិ ដែលតម្រូវអោយមានទំហំព្រៃឈើបម្រុងទុកអោយបានគ្រប់គ្រាន់ សម្រាប់ទុបទុលការប្រើប្រាស់របស់ប្រជាពលរដ្ឋ ការពារភាពរាំងស្ងួត និងទឹកជំនន់ ព្រមទាំងព្រៃលិចទឹកសម្រាប់ទុកជាជម្រកមច្ឆាជាតិ
- ប្រព័ន្ធការពារធនធានធម្មជាតិ ដើម្បីធ្វើការអភិរក្សជីវសាស្ត្រចំរុះនឹងប្រភេទដែលមានដោយកម្រ

- អនុវត្តកម្មវិធីអភិវឌ្ឍន៍សហគមន៍ព្រៃមួយដែលរឹងមាំ មានតម្លាភាព និងមានការគ្រប់គ្រងដោយប្រជាពលរដ្ឋ ដោយផ្ទាល់ក្នុងតំបន់

## ២. វិស័យជលផល និងនេសាទ

- កែទម្រង់វិស័យជលផល
- ជំរុញការបង្កើតកន្លែងអភិរក្សពូជត្រី
- ជំរុញការអភិវឌ្ឍន៍វារីវប្បកម្ម

# ២. សមិទ្ធិផល និងការអនុវត្តច្បាប់

## ១. ព្រៃឈើ :

- គ្របដណ្តប់ជាងពាក់កណ្តាលផ្ទៃដីប្រទេសកម្ពុជា សំបូរទៅដោយប្រភេទឈើមានតម្លៃ សត្វព្រៃ និងជីវចំរុះ
- ប្រជាជនប្រមាណ ៨៥ ភាគរយ រស់នៅជនបទ ពឹងផ្អែកលើរបរកសិកម្ម និងផល-អនុផលព្រៃឈើ
- ចូលរួមចំណែកក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមនៃប្រទេសកម្ពុជា ក្នុងនោះ ព្រៃឈើចូលរួមប្រមាណ ៧ ភាគរ នៃ GDP កសិកម្ម

# ២. សមិទ្ធិផល និងការអនុវត្តច្បាប់

## ១. ព្រៃឈើ ៖

- កសាងច្បាប់ព្រៃឈើ-លិខិតបទដ្ឋាន-បទដ្ឋានបច្ចេកទេសផ្សេងៗ
- មានវិធានការម៉ឺងម៉ាត់ក្នុងការទុបស្កាត់ បង្ក្រាប់បទល្មើសព្រៃឈើ សត្វព្រៃ ដោយចាប់ឃាត់រឹបអូសបានវត្ថុតាងបទល្មើស ជនប្រព្រឹត្តិបទល្មើស
- ដកហូតព្រៃសម្បទាន និងលុបកិច្ចព្រមព្រៀងព្រៃសម្បទាន ១៧ ក្រុមហ៊ុន ផ្ទៃដី ៣.៥00.000 ហ.ត ធ្វើជាតំបន់ការពារ និងអភិរក្សព្រៃឈើជាង ១.៣ លាន ហ.ត បន្ថែមលើតំបន់ការពារ ២៣ កន្លែង បាន ៤.៥ លាន ហ.ត (២៥ ភាគរយ នៃផ្ទៃដីប្រទេស)

# ២~ សមិទ្ធិផល និងការអនុវត្តច្បាប់

## ១~ ព្រៃឈើ :

- ឆ្នាំ ២០០៧ រៀបចំព្រៃគុប ៤ កន្លែង
- សមាហរណកម្មវិស័យព្រៃឈើក្នុងសហគមន៍អន្តរជាតិ : ITTO, CITES, RAMSAR, CBD, UNCCD, UNFCC, SEAZA, APAFRI, ASOF, ASGM, UNFF
- សហប្រតិបត្តិការជិតស្និតក្នុងតំបន់អាស៊ាន និងពិភពលោក
- ដក់ហូតព្រៃឈើកាន់កាប់ដោយខុសច្បាប់ជាង ២០ ម៉ឺន ហិកតា ទុកសម្រាប់គោលដៅដាំឈើឡើងវិញ ធ្វើជាសម្បទានដីសង្គមកិច្ច ឬសេដ្ឋកិច្ច
- រៀបចំសហគមន៍ព្រៃឈើគ្រប់គ្រងដោយប្រជាជន ៣០០ កន្លែង ផ្ទៃដី ១៨១.០០០ ហ.ត ប្រជាជនប្រមាណ ៦២.៤០០ គ្រួសារ

# ការលំបាក និងភាពប្រឈមមុខ :

- សង្គ្រាម និងទំនាស់ផ្ទៃក្នុងជាងពីរទសវត្សកន្លងមកបានដាក់កម្ពុជាធ្ងន់ធ្ងរលើវិស័យព្រៃឈើ និងជលផល
- ការកាប់រានដុត-ឈូសឆាយ និងហ៊ុមព័ទ្ធដីព្រៃឈើធ្វើជាកម្មសិទ្ធិ
- ធនធានមនុស្សមិនគ្រប់គ្រាន់តាមតម្រូវការការងារ
- ធនធានថវិកា មធ្យោបាយ និងសម្ភារៈសម្រាប់ដំណើរការគ្រប់គ្រង អភិរក្ស និងការពារព្រៃឈើនៅមានកំរិត
- ជីវភាពពឹងអាស្រ័ដោយព្រៃឈើនៅមានកំរិតខ.ស់
- ការយល់ដឹងអំពីច្បាប់នៅមានកំរិត

# វិធានការ និងដំណោះស្រាយ :

- ពង្រឹងការគ្រប់គ្រងព្រៃឈើ និងអភិរក្សធនធានព្រៃឈើ
- ជំរុញព្រៃឈើអោយចូលរួមអភិវឌ្ឍន៍កាត់បន្ថយភាពក្រីក្រ
- ពង្រឹងសមត្ថភាពនិងអភិបាលកិច្ចល្អក្នុងវិស័យព្រៃឈើ

# ២. វិស័យជលផល

- វិស័យជលផលដើរតួនាទីដ៏សំខាន់សម្រាប់ប្រជាជនកម្ពុជា
- ជលផលជាប្រភពចំបងនៃអាហារូបត្ថម្ភក្នុងរបបអាហារប្រចាំថ្ងៃ ផ្តល់ប្រូតេអ៊ីនសាច់ ៨0 ភាគរយ និងជាប្រភពចំណូល ដ៏សំខាន់ (២៥.៩ ភាគរយ នៃ GDP កសិកម្ម)
- វិស័យជលផលបានផ្តល់នូវមុខរបរដល់ប្រជាពលរដ្ឋជាង ៦ លាន នាក់ដែលស្មើនឹង ៤៥.៥ ភាគរយ នៃប្រជាជនទូទាំងប្រទេស (១0.៥ ភាគរយ សម្រាប់នេសាទជាលក្ខណៈអាជីព និង ៣៥ ភាគរយ សម្រាប់ការនេសាទចិញ្ចឹមជីវិត ។

# ២. វិស័យជលផល

- ផលិតផលត្រីទឹកសាបប្រទេសកម្ពុជា ត្រូវបានជាប់ចំណាត់ថ្នាក់ទី៤លើពិភពលោក បន្ទាប់ពីប្រទេសចិន ឥណ្ឌា និង បង់ក្លាដេស
- ប្រជាជនកម្ពុជាម្នាក់ៗហូបត្រីជាមធ្យមគិតជាស្រស់អស់ ៣៧.៥ គ.ក្រ/ឆ្នាំ (ខ្ពស់ជាងពិភពលោកដែលមានជាមធ្យម ១៥ គ.ក្រ/ឆ្នាំ ប៉ុណ្ណោះ)
- ផលិតផលត្រីទឹកសាបសរុបនៃប្រទេសកម្ពុជាមានជាង ៤00.00 តោន/ឆ្នាំ ដែលមានតម្លៃជាង ៣00 លាន ដុល្លារអាមេរិក និងផលិតផលត្រីសមុទ្រមានជាង ៦0.000 តោន/ឆ្នាំ វារីវប្បកម្ម ៣៥.000 តោន/ឆ្នាំ
- ច្បាប់ជលផល និងបទដ្ឋានផ្សេងៗ

# ២. វិស័យជលផល

- លុបឡូត៍នេសាទជាង ៥៦ ភាគរយ ស្មើនឹង ៥៣៨.៣២២ ហ.ត ជូនប្រជាជន
- បង្កើតសហគមន៍នេសាទ ៥០៩
- រៀបចំផែនទី កំណត់តំបន់នាទីព្រៃលេចទឹក ព្រៃកោងកាង
- រៀបចំតំបន់អភិរក្សជលផល (១៨ កន្លែង) ផ្សោត ត្រីមេពូជ ។ល។
- បង្ក្រាបបទល្មើសនេសាទគ្រប់ប្រភេទ

# បញ្ហាប្រឈមមុខក្នុងវិស័យជលផល

- ការថយចុះព្រៃលិចទឹក និងព្រៃកោងកាងដែលជាជំរកពងកូន រកចំណី និងលូតលាស់ មច្ឆាជាតិបណ្តាលមកពីការកាប់រានព្រៃលេចទឹក និងព្រៃកោងកាង យកដីធ្វើជាកម្មសិទ្ធិ និងធ្វើស្រែចំការ

- ផលស្តុកត្រីធម្មជាតិមានការថយចុះ ដែលបណ្តាលមកពី :

  - សំពាធលើការនេសាទមានកំរិតខ្ពស់បំផុត

  - ប្រជាជនកើនឡើង ប្រជានេសាទកើនឡើង ឧបករណ៍នេសាទកើនឡើង

# បញ្ហាប្រឈមមុខក្នុងវិស័យជលផល :

- តម្រូវការត្រីក្នុងស្រុក និងក្រៅស្រុកកើនឡើង
- ការនេសាទដោយប្រើឧបករណ៍ទំនើប និងខុសច្បាប់
- ការអនុវត្តន៍ច្បាប់របស់ស្ថាប័នជំនាញ និងអាជ្ញាធរមូលដ្ឋាននៅមានកំរិត

## វិធានការ ៖

ក- បញ្ហាព្រៃលេចទឹក និងព្រៃកោងកាង ៖

ខ- បញ្ហាធនធានជលផលថយចុះ

គ- បញ្ហាសំណង់វារីអគ្គីសនី និងធារាសាស្ត្រ

ឃ- បញ្ហាសាយភាយនៃពូជត្រីក្រៅស្រុក

ង- បញ្ហាបំរែបំរួលអាកសាធាតុ